ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.................. សហវ....

រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ.........ឆ្នាំ ២០០១

# ប្រកាស

## ស្តីពី

## ការប្រើប្រាស់ ស្លាកយីហោរបស់ ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញការចាំបាច់នៃការងារគ្រប់គ្រង ។

នាយកដ្ឋានឧទ្ទេសស្ថាបនាបសេដ្ឋកិច្ចហិរញ្ញវត្ថុ

សំរេច

ប្រការ ១-

អនុលោមតាមមាត្រា ៤ នៃច្បាប់ស្តីពីការធានារ៉ាប់រងបុគ្គលទាំងឡាយដែលអាចប្រកបអាជីវកម្មធានារ៉ាប់រងបានរួមមាន ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ។

ប្រការ ២-

ក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទ ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រងដែលបានទទួលការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជាត្រូវប្រើប្រាស់ "ស្លាកយីហោ" ក្រុមហ៊ុនឱ្យបានត្រឹមត្រូវតាមអាជ្ញាប័ណ្ណដែលបានផ្តល់ជូនទោះនៅទីស្នាក់ការក្រុមហ៊ុន ឬនៅលើឯកសារដែលត្រូវចែកផ្សាយដល់សាធារណជន និងតាមរយៈការផ្សាយពាណិជ្ជកម្មផ្សេងៗ ។

ប្រការ ៣-

ចំពោះក្រុមហ៊ុនដែលជាភ្នាក់ងារធានារ៉ាប់រង ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នៅពីមុខ ឬ នៅពីក្រោយ ឬ នៅពីក្រោមឈ្មោះក្រុមហ៊ុននូវពាក្យថា "ភ្នាក់ងារធានារ៉ាប់រង" ។

ក្នុងករណីដែលមិនបានបញ្ជាក់ច្បាស់នូវពាក្យថា "ភ្នាក់ងារធានារ៉ាប់រង" នៅតាមទីកន្លែងដូចបានលើកឡើងនៅវាក្យខ័ណ្ឌទី១នៃប្រការនេះទេ ចាត់ទុកថាសាមីក្រុមហ៊ុនភ្នាក់ងារនោះមានចេតនាក្លែងបន្លំឯកសារដើម្បីធ្វើឱ្យមានការភ័ន្តច្រឡំដល់សាធារណជន ។

ប្រការ ៤-

ចំពោះក្រុមហ៊ុនដែលជាជើងសាធានារ៉ាប់រង ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ជាមួយនឹងឈ្មោះក្រុមហ៊ុននូវពាក្យថា "ជើងសាធានារ៉ាប់រង" ។

ក្នុងករណីដែលមិនបានបញ្ជាក់ច្បាស់នូវពាក្យថា " ជើងសាធានារ៉ាប់រង " នេះទេ ចាត់ទុកថាសាមីក្រុមហ៊ុនជើងសានោះ មានចេតនាក្លែងបន្លំឯកសារដើម្បីធ្វើឱ្យមានការភ័ន្តច្រឡំដល់សាធារណជន ។

ប្រការ ៥-

ក្នុងករណីមានក្រុមហ៊ុនណាមួយ ប្រើប្រាស់ស្លាកយីហោក្រុមហ៊ុនមិនបានត្រឹមត្រូវតាមអាជ្ញាប័ណ្ណដែលបានផ្តល់ជូនទេ ទោះបីក្នុងកាលៈទេសៈណាក៏ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចាត់វិធានការសមស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានចំពោះសាមីក្រុមហ៊ុននោះ ។

ប្រការ ៦-

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧.-

ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។/.

នាយកដ្ឋាន[illegible]

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ឯកសារ - កាលប្បវត្តិ